# ព្រះរាជក្រម

នស/រកម/០៧០២/០១៣

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីការកំណត់ចំនួនអាសនៈរដ្ឋសភា នីតិកាលទី៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គលើក ទី៨ នីតិកាល ទី២ ហើយដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យអត្ថបទច្បាប់នេះ ឱ្យទាន់តាមកាលកំណត់របស់មាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញឡើយ ។

ច្បាប់នេះមានសេចក្ដីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

## ការកំណត់ចំនួនអាសនៈរដ្ឋសភា នីតិកាលទី ៣

**មាត្រា ១.-**

ចំនួនអាសនៈរដ្ឋសភានីតិកាលទី ៣ ត្រូវកំណត់ត្រឹមមួយរយម្ភៃបី (១២៣)។

**មាត្រា ២.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៦ ខែកក្កដាឆ្នាំ ២០០២

ក្នុងព្រះបរមនាម

និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

នសរ.០៧០២.០០៧៦

**ព្រះមហាក្សត្រលេខា និង ព្រះរាជលញ្ចករ**

**នរោត្តម រណឫទ្ធិ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១៦៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ាវឌី តាន់**